ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃចន្ទ ៣ កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០២២

# សេចក្តីជូនដំណឹងដល់សាធារណៈជន

## ស្តីពី ការដាក់ដេញថ្លៃជាសាធារណៈ ជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកជុំ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានកិត្តិយសជម្រាបជូនសាធារណៈ ទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានសហការជាមួយកម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) ដែលទទួលជំនួយឥតសំណងពីក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃរដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងធ្វើការសិក្សាផ្គត់ផ្គង់ទឹកជុំ នៅឃុំទួលព្រេជ និងឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាលនិងឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

ក្រសួងសូមប្រកាសជូនដំណឹងដាក់ដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកជុំ នៅឃុំទាំងបីខាងលើ ក្នុងការផ្គត់ផ្គង់ទឹកជុំជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតពីរូប ដែលមានលក្ខខណ្ឌ ដូចខាងក្រោមនេះ ៖

១- ទុនវិនិយោគសរុប៖ **១ ១៣៣ ៩៦០ ដុល្លារអាមេរិក** សម្រាប់អនុវត្តគម្រោងរយៈពេល **៥ឆ្នាំ**

២- អ្នកចូលរួមត្រូវមាន៖ ទុនវិនិយោគយ៉ាងតិច **៣៥% នៃទុនវិនិយោគសរុប ឬ ៣៩៦ ៨៨៦ ដុល្លារអាមេរិក**

៣- ប្រាក់កក់ធានាចូលរួមដេញថ្លៃ៖ **៥ ០០០ដុល្លារអាមេរិក** (មានលិខិតបញ្ជាក់ពីធនាគារ)

៤- ថវិកាឧបត្ថម្ភពីគម្រោង (3i)៖ **៤១២ ៣៨០ ដុល្លារអាមេរិក** (ឧបត្ថម្ភតាមលទ្ធផលនៃជំហាននីមួយៗ)

៥- ថ្លៃលក់ទឹក (ដេញថ្លៃ)៖ **ថ្លៃលក់ ចន្លោះពី ១ ៤០០ ៛/ម៣ ដល់ ១ ៦០០ ៛/ម៣**

៦- ព័ត៌មានលម្អិតមានក្នុងឯកសារដេញថ្លៃ ដែលអាចរកជាវបាននៅនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ លោកអ្នកក៏អាចស្វែងរកព័ត៌មានសង្ខេបថ្មីសំខាន់ៗ ក្នុងគេហទំព័រ៖ www.3icambodia.org

៧- កិច្ចប្រជុំណែនាំស្តីពីការរៀបចំឯកសារចូលរួមដេញថ្លៃនឹងប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង៖ ៩:០០ នាទីព្រឹកនៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៩:០០ នាទីព្រឹក នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាកំហិត។

ឧ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា
និងនវានុវត្តន៍
រដ្ឋលេខាធិការ

ស៊ឹម ស៊ីថា

**ទំនាក់ទំនង៖**

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
  លោក សឿង យុត្តិ៍
  Tall: 092 768 699
- កម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i)
  Tall: 081 222 707
  អ៊ីមែល៖ info@3icambodia.org